ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០២៣ សហវ.អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១២

# សេចក្តីជូនដំណឹង

## ស្តីពី

## ការកែសម្រួលការបង់ប្រាក់ពន្ធលើអចលនទ្រព្យ

ដើម្បីសម្រួលដល់ការបង់ប្រាក់ពន្ធលើអចលនទ្រព្យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការកែសម្រួល សេចក្តីជូនដំណឹង លេខៈ ០២២ សហវ.អពដ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២ ដោយអនុញ្ញាតឱ្យម្ចាស់អចលនទ្រព្យ អាចបង់ប្រាក់ពន្ធលើអចលនទ្រព្យ ដូចខាងក្រោម÷

- អាចបង់ដោយផ្ទាល់នៅបេឡាសាខាពន្ធដារខេត្ត-ខណ្ឌ ដែលអចលនទ្រព្យនោះស្ថិតនៅ ឬ
- អាចបង់តាមប្រព័ន្ធធនាគារ តាមការណែនាំរបស់សាខាពន្ធដារខេត្ត-ខណ្ឌ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមថា សេចក្តីជូនដំណឹងនេះ នឹងជួយសម្រួលដល់ លោក-លោកស្រី ដែលជាម្ចាស់អចលនទ្រព្យ ឱ្យកាន់តែមានភាពងាយស្រួល និងឆាប់រហ័ស ក្នុងការបង់ប្រាក់ពន្ធលើអចលនទ្រព្យ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

Collection by VCAT Professional Consultant

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798